រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

027KH01A-01

ការចេញទៅផ្សព្វផ្សាយដំណឹងល្អ ដល់គ្រប់ជាតិសាសន៏



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

២៧

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ទូលសូមអោយព្រះជាម្ចាស់ប្រើការសិក្សានេះ ដើម្បីរៀបចំក្រុមជំនុំរបស់អ្នកអោយចេះផ្គត់ផ្គង់បេសកកម្មគ្រីស្តទូត និងចាត់គ្រីស្តទូតអោយចេញទៅ ។

មហាបណ្តាំនៅក្នុងសម្ពន្ធមេត្រីចាស់

ព្រះយេស៊ូគ្រីស្តបង្គាប់យើងថា÷ *«...ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ឱ្យធ្វើជាសាវ័ក...»* (ម៉ាថាយ ២៨:១៩) ។ យើងឃើញពីផែនការរបស់ព្រះជាម្ចាស់ សំរាប់ការផ្សាយដំណឹងល្អពេញពិភពលោក តាំងពីនៅក្នុងសៀវភៅទីមួយរបស់ព្រះគម្ពីរម្ល៉េះ ។ យោងទៅតាមកាឡាទី ៣:៨ ព្រះជាម្ចាស់បានប្រកាសដំណឹងល្អទៅលោកអប្រាហាំហើយ ។ នៅក្នុងកំណើតពិភពលោក ១២:១-៣ ព្រះជាម្ចាស់សន្យានឹងលោកអប្រាហាំថា គ្រប់ជាតិសាសន៍លើពិភពលោកនឹងបានទទួលព្រះពរតាមរយៈពូជពង្សរបស់គាត់ ។ ក្រោយមក ព្រះជាម្ចាស់រំលឹកពាក្យសន្យានេះម្តងទៀត នៅពេលដែលអប្រាហាំបានស្ម័គ្រចិត្ត យកអ៊ីសាក់ធ្វើជាយញ្ញបូជា តាមសេចក្តីបង្គាប់របស់ព្រះជាម្ចាស់ ។

កំណត់ចំណាំ :

© Project WorldReach © SEAN

- ដើម្បីរៀបចំបណ្តុះបណ្តាលសមាជិកខ្លះរបស់អ្នក ដែលបានទទួលការត្រាស់ហៅរបស់ព្រះជាម្ចាស់ អោយធ្វើជាគ្រីស្តទូតនៅក្នុងទីក្រុងរបស់ពួកគេ ឬ ក្នុងប្រទេស ឬ នៅប្រទេសក្រៅ សូមបន្តបង្ហាត់បង្រៀនតាមកិរិត ទី ៣ របស់កម្មវិធី «ការបង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត» ។ (សូមមើលសៀវភៅណែនាំសកម្មភាពពួកអ្នកសិក្សា) ។

កំណត់ចំណាំ :



«ប្រជាជាតិទាំងប៉ុន្មាននៅលើផែនដីនឹងពោលថា គេបានទទួលពរតាមរយៈពូជពង្សរបស់អ្នក» ។

(កំណើតពិភពលោក ២២:១៨)

នៅក្នុងព្រះគម្ពីរពាក្យ «ប្រជាជាតិ» សំដៅទៅលើជាតិសាសន៍ (មិនមែនទៅលើប្រទេសទេ) ។ តើយើងអាចឃើញពាក្យសន្យាថា *«ប្រជាជាតិទាំងប៉ុន្មាននៅលើផែនដី នឹងបានទទួលពរ»*ជាលើកដំបូងនៅក្នុងបទគម្ពីរណា ?

នៅក្នុងបទគម្ពីរ _____

សូមគូសសញ្ញា «✓»នេះ នៅនឹងចំលើយដែលត្រឹមត្រូវ :

ពាក្យ «ជាតិសាសន៍ » នៅក្នុងមហាបណ្តាំ ក្នុងម៉ាថាយ ២៨:
១៨-២០ មានន័យថា :

☐ ក្រុមមនុស្ស មានវប្បធម៌ ភាសា និងជាតិសាសន៍ដូចគ្នា ។

☐ ប្រទេសដែលមានព្រំដែនកំណត់ ។

នៅក្នុងសម្ពន្ធមេត្រីចាស់ ពួកកូនចៅរបស់លោកអាប្រាហាំ (ពួក
អ៊ីស្រាអែល) មិនបានធ្វើតាមមុខនាទីរបស់ខ្លួន ជាឧបករណ៍របស់
ព្រះជាម្ចាស់ សំរាប់ធ្វើឱ្យសំរេចព្រះបន្ទូលសន្យាថា ព្រះជាម្ចាស់
នឹងប្រទានពរដល់គ្រប់ជាតិសាសន៍លើពិភពលោកនោះទេ ។
ផ្ទុយទៅវិញ ពួកគេមិនស្តាប់បង្គាប់ព្រះជាម្ចាស់ បែរជាទៅថ្វាយ
បង្គំព្រះក្លែងក្លាយ តាមពួកសាសន៍ដទៃ ដែលរស់នៅជិតខាងខ្លួន
ទៅវិញ ។

ក្រោយមក ព្យាការីយ៉ូណាសជិះកប៉ាល់រត់គេចមិនព្រមទៅប្រកាស
ព្រះបន្ទូលនៅទីក្រុងនីនីវេ ដែលមានជនជាតិសាសន៍ដទៃរស់នៅ
ទេ ។

កិច្ចការដែលត្រូវអនុវត្ត

- ទន្ទេញកំណើតពិភពលោក ២២:១៨ : *«ប្រជាជាតិទាំង
ប៉ុន្មាននៅលើផែនដីនឹងពោលថា គេបានទទួលពរតាមរយៈ
ពូជពង្សរបស់អ្នក ព្រោះអ្នកបានស្តាប់បង្គាប់យើង »* ។
- សូមចែកចាយប្រាប់ក្រុមជំនុំរបស់អ្នកអំពីទឹកចិត្តនិមិត្តឃើញ
របស់អ្នក អំពីការផ្សាយដំណឹងល្អទៅគ្រប់ជាតិសាសន៍ និង
បង្រៀនអត្ថបទសិក្សានេះដល់ពួកគេ ។
- អធិស្ឋានសំរាប់ការងារគ្រីស្តទូត ជាទៀងទាត់ជាមួយក្រុម
ជំនុំទាំងមូល ។
- លើកដង្វាយប្រចាំខែ សំរាប់ផ្គត់ផ្គង់ការងារគ្រីស្តទូត នៅ
ក្រៅប្រទេស ។
- លើកទឹកចិត្តជំរុញអោយក្រុមជំនុំ ចេះរៀបចំបណ្តុះបណ្តាល
និងចាត់គ្រីស្តទូតអោយចេញទៅ ។
- អោយក្រុមជំនុំរបស់អ្នកខិតខំធ្វើកិច្ចការសាសនទូត ចំពោះ
ជាតិសាសន៍ណាមួយ ដែលមិនទាន់បានឮដំណឹងល្អ ។



«គេនឹងប្រកាសដំណឹងល្អអំពីព្រះរាជ្យនេះ ពាសពេញសកលលោកទាំងមូល ទុកជាសក្ខីភាពដល់ជាតិសាសន៍ទាំងអស់ ។ ពេលនោះ ទើបអវសានកាលនៃពិភពលោក » ។

(ម៉ាថាយ ២៤:១៤)

ដូច្នេះ យើងឃើញថា ដោយសារពួកសាសន៍អ៊ីស្រាអែលមិនស្តាប់បង្គាប់ព្រះជាម្ចាស់ គេមិនបានក្លាយជាឧបករណ៍របស់ព្រះជាម្ចាស់ដើម្បីអោយគ្រប់ជាតិសាសន៍បានទទួលព្រះពរ តាមរយៈពួកគេនោះទេ ។



នៅក្នុងសម្ពន្ធមេត្រីចាស់ តើអ្នកណាទទួលខុសត្រូវក្នុងការចែកចាយព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ ដែលថាព្រះអង្គនឹងប្រទានព្រះពរដល់គ្រប់ជាតិសាសន៍ តែមិនបានធ្វើភារៈកិច្ចនេះ ?

☐ ពួកកូនចៅអ៊ីស្រាអែល ។

☐ ពួកសាសន៍អេដុំ ។

ប៉ុន្តែ បើព្រះជាម្ចាស់សំរេចធ្វើកិច្ចការណាមួយហើយ គ្មានអ្វីអាចរារាំងព្រះអង្គបានឡើយ ។ អេសាយ ៤៩:៦ចែងថា÷«*...គឺយើងតែងតាំងអ្នកឱ្យធ្វើជាពន្លឺសំរាប់បំភ្លឺប្រជាជាតិទាំងឡាយ ហើយនាំការសង្គ្រោះរបស់យើងរហូតដល់ស្រុកដាច់ស្រយាលនៃផែនដី* »។ សេចក្តីសង្គ្រោះដ៏អស់កល្បមិនមែនបានមក ដោយសារសាសន៍អ៊ីស្រាអែលទាំងមូលទេ តែបានមកដោយសារជនជាតិអ៊ីស្រាអែលតែម្នាក់ ដែលជាពូជពង្សរបស់លោកអាប្រាហាំ គឺព្រះយេស៊ូដែលជាព្រះបុត្រារបស់ព្រះជាម្ចាស់ ។ ព្រះយេស៊ូជាព្រះមេស៊ី ជាព្រះ-មហាក្សត្រ ដែលព្រះជាម្ចាស់លាបប្រេងតាំង និងចាត់តាំងអោយប្រទានព្រះពរដល់មនុស្សគ្រប់ជាតិសាសន៍ ។

មហាបណ្តាំនៅក្នុងសម្ពន្ធមេត្រីថ្មី

ព្រះយេស៊ូគ្រីស្តយាងមក ដើម្បីធ្វើអោយផែនការអស់កល្បរបស់ព្រះជាម្ចាស់បានសំរេច ។ សេចក្តីបង្គាប់ចុងក្រោយរបស់ព្រះ-យេស៊ូចំពោះសាវ័ករបស់ព្រះអង្គ គឺអោយគេចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍អោយធ្វើជាសាវ័ក ។ សេចក្តីនេះ ជាការសំរេចតាមព្រះបន្ទូលសន្យាចំពោះលោកអប្រាហាំ តាំងពីយូរណាស់មកហើយ ។ ព្រះអម្ចាស់យេស៊ូបានមានបន្ទូលថា÷

បន្ទាប់មក ខ្ញុំឮព្រះសូរសៀងរបស់ព្រះអម្ចាស់ដែលមានព្រះបន្ទូលថា÷ «តើយើងនឹងចាត់អ្នកណាអោយទៅ តើនរណានឹងនាំពាក្យរបស់យើង ? » ខ្ញុំទូលឆ្លើយថា÷ «*ទូលបង្គំនៅទីនេះស្រាប់ហើយ សូមព្រះអង្គចាត់ទូលបង្គំចុះ !* » (អេសាយ ៦:៨) ។

សព្វថ្ងៃ ព្រះជាម្ចាស់មានបន្ទូលសួរក្រុមជំនុំរបស់ព្រះអង្គថា÷

«*"ជ្បិតអ្នកណាអង្វរករព្រះនាមព្រះអម្ចាស់ អ្នកនោះនឹងទទួលការសង្គ្រោះ"។ ក៏ប៉ុន្តែ អោយគេអង្វរកព្រះអង្គដូចម្តេចកើត បើគេមិនជឿ ? អោយគេជឿលើព្រះអង្គដូចម្តេចកើត បើគេមិនដែលឮព្រះអង្គមានព្រះបន្ទូល ? អោយគេឮដូចម្តេចកើត បើគ្មាននរណាប្រកាស ? អោយមានអ្នកប្រកាសដូចម្តេចកើត បើគ្មាននរណាចាត់អោយទៅប្រកាសផងនោះ ? ដូចមានចែងទុកថា÷ "មើល៍អ្នកដែលធ្វើដំណើរនាំដំណឹងដ៏ល្អៗមក ប្រសើររុងរឿងណាស់ហ្ន៎ !"*» ។

(រ៉ូម ១០:១៣-១៥)

ក្រុមជំនុំនៅស្រុកអន់ទីយ៉ូកបានតមអាហារ និងអធិស្ឋានដាក់ដៃលើលោកប៉ូល និងលោកបាណាបាស ទើបព្រះជាម្ចាស់ប្រទានអោយលោកទាំងពីរមានឫទ្ធានុភាពឈ្នះលើឧបសគ្គគ្រប់យ៉ាង (កិច្ចការ ១៣:៣) ។

តើក្នុងចំណោមឧបសគ្គដែលមានរៀបរាប់ខាងលើ ឧបសគ្គណាមួយ ដែលអ្នកពិបាកឆ្លងកាត់ជាងគេ ? ព្រោះអ្វី ?

តើអ្នកអាចឆ្លងកាត់ឧបសគ្គនេះ យ៉ាងដូចម្តេចបាន ?

ព្រះជាម្ចាស់ស្វែងរកអស់អ្នកណាដែលមានជំនឿ ដើម្បីសំរេចផែនការរបស់ព្រះអង្គ ក្នុងការប្រទានពរដល់គ្រប់ជាតិសាសន៍ទាំងអស់នៅលើពិភពលោក ។

«គេនឹងប្រកាសដំណឹងល្អអំពីព្រះរាជ្យនេះពាសពេញសកលលោកទាំងមូល ទុកជាសក្ខីភាពដល់ជាតិសាសន៍ទាំងអស់ ។ ពេលនោះទើបដល់អវសានកាលនៃពិភពលោក »

(ម៉ាថាយ ២៤:១៤)

យោងទៅតាម កាឡាទី ៣:២៩ តើសព្វថ្ងៃនេះ អ្នកណាជាពូជពង្សរបស់លោកអាប្រាហាំ ហើយអ្នកណាជាអ្នកទទួលព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ចំពោះលោកអាប្រាហាំ ?

ទំព័រចុងក្រោយទាំងប៉ុន្មានរបស់ព្រះគម្ពីរ បង្ហាញពីពួកអ្នកដែលនឹងទៅជួបជុំគ្នានៅមុខបល្ល័ង្ករបស់ព្រះជាម្ចាស់ (វិវរណៈ ៧:៩)។

«ក្រោយមកទៀត ខ្ញុំមើលទៅឃើញមហាជនដ៏ច្រើនកុះករ គ្មាននរណាអាចរាប់ចំនួនបានឡើយ អ្នកទាំងនោះមកពីគ្រប់ជាតិ-សាសន៍ គ្រប់កុលសម្ព័ន្ធ គ្រប់ប្រជាជន និងពីគ្រប់ភាសា ។ ពួកគេពាក់អាវសវែង ឈរនៅមុខបល្ល័ង្ក និងនៅមុខកូនចៀម...» ។

ផែនការរបស់ព្រះជាម្ចាស់ និងសេចក្តីបង្គាប់របស់ព្រះអម្ចាស់-យេស៊ូ នឹងបានសំរេចក្នុងពេលឆាប់ៗ ! (វិវរណៈ ២២:២០) ។



សូមស្វាគមន៍ដល់គ្រប់ជាតិសាសន៍ !

យើងអាចឃើញផែនការដ៏អស់កល្បរបស់ព្រះជាម្ចាស់ ដើម្បីប្រទានព្រះពរដល់គ្រប់ជាតិសាសន៍លើពិភពលោក នៅពេញក្នុងព្រះគម្ពីរ ។ យើងឃើញដំបូងនៅក្នុងសៀវភៅ _____ ហើយបន្តរហូតដល់សៀវភៅ _____ ។



ឧបសគ្គទាំងអស់នោះធំណាស់ ។ គ្មានអ្នកណាអាចឆ្លងកាត់ឧបសគ្គទាំងនេះបានទេ លើកលែងតែអ្នកដែលក្រុមជំនុំចាត់ឱ្យទៅដោយអធិស្ឋានច្រើន និង ដោយជំនឿ ។

© Project WorldReach © SEAN

៥- ឧបសគ្គដែលបណ្តាលមកពីភាពអាត្មានិយម និង ការភ័យខ្លាច

ព្រះយេស៊ូគ្រីស្តប្រាប់យើងអោយមើលទៅស្រែ ដែលដល់ពេលច្រូតហើយ (យ៉ូហាន ៤:៣៥) ។ ប៉ុន្តែ ក្រុមជំនុំខ្លះមើលតែទៅសេចក្តីត្រូវការរបស់ប្រជាជនខ្លួនផ្ទាល់តែ---- ប៉ុណ្ណោះ ។ ពួកគេមើលមិនឃើញស្រែធំទូលាយ ដែលមិនទាន់ឮដំណឹងល្អនៅកន្លែងផ្សេងទេ ។

អារក្សនាំឱ្យគ្រីស្តជនទន់ខ្សោយ ឱ្យនៅតែមួយកន្លែង មិនឆ្លងឧបសគ្គនេះទេ ។ មានគ្រីស្តទូតរាប់ពាន់នាក់ ប៉ុន្តែ មានតែមួយចំនួនតូចប៉ុណ្ណោះ ដែលចេញទៅរកជាតិសាសន៍ ដែលមិនទាន់ឮដំណឹងល្អ ។ ក្នុងចំណោមគ្រីស្តទូតដប់នាក់ប្រាំ-បួននាក់ទៅកន្លែងដែលមានក្រុមជំនុំហើយ ។ ក្នុងដប់នាក់មានតែម្នាក់ប៉ុណ្ណោះ ដែលចេញទៅរកជាតិសាសន៍ ដែលមិនទាន់ឮដំណឹងល្អ ។ សេចក្តីដែលសំខាន់បំផុត គឺចេញទៅទីកន្លែងដែលព្រះជាម្ចាស់ដឹកនាំអោយទៅ មិនមែនលាក់ខ្លួន ដោយសារលេសគ្រប់យ៉ាងនោះទេ ។

មហាបណ្តាំនៅក្នុងសៀវភៅកិច្ចការ

សៀវភៅកិច្ចការរបស់ពួកសាវ័កចែងប្រាប់យើងពីរបៀប ដែលពួកសាវ័កចាប់ផ្តើមអនុវត្តមហាបណ្តាំ ។ សៀវភៅនេះ រំលឹកពីសេចក្តីបង្គាប់របស់ព្រះអម្ចាស់យេស៊ូគ្រីស្ត នៅក្នុងជំពូកទីមួយ (កិច្ចការ ១:៨) ។

ឥឡូវនេះ សូមទន្ទេញ ខ នេះអោយចាំ :

«ប៉ុន្តែ អ្នករាល់គ្នានឹងទទួលបុព្វានុភាពមួយ គឺបុព្វានុភាពនៃព្រះ-វិញ្ញាណដ៏វិសុទ្ធមកសណ្ឋិតលើអ្នករាល់គ្នា ។ អ្នករាល់គ្នានឹងធ្វើជាបន្ទាល់របស់ខ្ញុំ នៅក្នុងក្រុងយេរូសាឡឹម ក្នុងស្រុកយូដាទាំងមូល នៅក្នុងក្រុងសាម៉ារី និងរហូតដល់ស្រុកដាច់ស្រយាលនៃផែនដី » ។

(កិច្ចការ ១:៨)

តើខណាមួយដែលជាកូនសោ នៅក្នុងសៀវភៅកិច្ចការ ?
កិច្ចការ ជំពូក_____ ខ _____

ខនេះសង្ខេបអំពីការចាប់ផ្តើម និងការរីកចំរើនរបស់ក្រុមជំនុំរបស់ព្រះយេស៊ូគ្រីស្ត ដែលមានរៀបរាប់ប្រាប់យើងនៅក្នុងសៀវភៅកិច្ចការនេះ ។

ស្បៀវភៅកិច្ចការ :



(ជំពូក ១ និង ២)

ពួកគេទទួលបច្ចាទុកភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីផ្សាយដំណឹងល្អអំពីព្រះអម្ចាស់យេស៊ូគ្រីស្ត ។

(ជំពូក ២ ដល់ ៧)

ពួកគេផ្សាយដំណឹងល្អ ដោយទឹកចិត្តក្លាហាន នៅក្នុងទីក្រុងយេរូសាឡឹម ។ នៅទីនោះ ក្រុមជំនុំក៏រីកចំរើនយ៉ាងឆាប់រហ័ស ។



៤- ឧបសគ្គដែលបណ្តាលមកពីការប្បែតប្បែន

នៅក្នុងទីកន្លែងដែលដំណឹងល្អមិនទាន់ទៅដល់ ពួកសាសនទូត និងអ្នកជឿថ្មីត្រូវជួបទុក្ខលំបាក ។ ការពិត រាល់ឆ្នាំមានគ្រីស្តជនរាប់ពាន់នាក់ស្លាប់នៅអាស៊ី ដោយសារគេមានជំនឿលើព្រះគ្រីស្ត (ចំនួននេះចេះតែកើនឡើងរាល់ឆ្នាំ) ។ ទៅអនាគត អ្នកជឿនឹងស្លាប់កាន់តែច្រើន ព្រោះអ្នកទាំងនោះ បានផ្តល់សក្ខីភាពអំពីព្រះយេស៊ូគ្រីស្ត (វិវរណៈ ៦:៩-១១, ១២:១៧, ១៧:៦) ។



៣- ឧបសគ្គដែលបណ្តាលមកពីមិនចេះភាសា

ជាតិសាសន៍ដែលមិនទាន់ឮដំណឹងល្អ និយាយភាសាផ្សេងៗ ។ ប្រពៃណីរបស់ពួកគេខុសផ្សេងពីប្រពៃណីរបស់យើង ។ យើងអាចផ្សាយដំណឹងល្អប្រាប់ពួកគេបានលុះត្រាតែយើងអត់ធ្មត់ ព្យាយាមរៀនប្រពៃណី និង ភាសារបស់ពួកគេអោយចេះច្បាស់សិន ។



(កិច្ចការ ៨:១-៤)

ពួកគេផ្សាយដំណឹងល្អនៅស្រុកយូដា និងស្រុកសាម៉ារី ដែលពួកគេរត់គេចខ្លួនទៅ ដោយសារត្រូវគេបៀតបៀន នៅក្នុងទីក្រុងយេរូសាឡឹម ។ ព្រះជាម្ចាស់ឱ្យព្រឹត្តិការណ៍នេះ កើតឡើងចំពោះពួកគេ ដើម្បីអោយពួកគេបានចេញទៅស្រុកជិតខាងផ្សព្វផ្សាយដំណឹងល្អ ។

(កិច្ចការ ៨:៤-២៥)

លោកភីលីពបានផ្សាយដំណឹងល្អនៅស្រុកសាម៉ារី ។ អ្នកស្រុកសាម៉ារីជាអ្នកស្រុកជិតខាង ដែលមានវប្បធម៌ និងសាសនាខុសពីពួកយូដា (អ៊ីស្រាអែល) ។ អ្នកស្រុកសាម៉ារី និងពួកយូដាតែងតែទាស់គ្នា ។

(ជំពូក ៨:២៦ ដល់ ២៨)

ពួកគេបានចាប់ផ្តើមផ្សាយដំណឹងល្អ ប្រាប់ជាតិសាសន៍ផ្សេងៗ ។

ដើម្បីអាចពង្រីកព្រះរាជ្យរបស់ព្រះយេស៊ូ ទៅដល់ជាតិសាសន៍នានា ព្រះជាម្ចាស់បានធ្វើការអស្ចារ្យលើលោកប៉ូល និងលោកពេត្រុស ដោយធ្វើអោយលោកទាំងពីរនាក់នោះលែងមានទឹកចិត្តប្រកាន់ពូជសាសន៍ និងប្រកាន់សាសនា (ជំពូក ៩ និង ១០) ។

លោកប៉ុលកែប្រែចិត្តគំនិតទាំងស្រុង នៅពេលដែលលោកបានថ្វាយខ្លួនប្រតិបត្តិតាមព្រះគ្រីស្ត ។

ព្រះជាម្ចាស់ធ្វើអោយលោកពេត្រុសលង់ស្មារតី និមិត្តឃើញហេតុ-ការណ៍មួយដល់ទៅបីដង ហើយក្នុងពេលនោះ ព្រះអង្គបង្គាប់អោយលោកបរិភោគសត្វទាំងឡាយ ដែលពួកយូដាចាត់ទុកថាមិនបរិសុទ្ធ ។ ព្រះជាម្ចាស់ធ្វើអោយគាត់សុខចិត្តទទួល និងផ្សាយដំណឹងល្អប្រាប់ជាតិសាសន៍ ដែលមិនមែនជាជនជាតិយូដា គឺប្រជាជ ដែលមានវប្បធម៌ សាសនា និង ប្រពៃណីផ្សេងដែលពួកយូដាចាត់ទុកថា មិនគួរទទួល ហើយមិនគួរទាក់ទងជាមួយ ។

តើការនិមិត្តឃើញរបស់លោកពេត្រុស នៅក្នុងកិច្ចការ ១០:៩-១៦ មានគោលបំណងដូចម្តេច ?

២- ឧបសគ្គដែលទាក់ទងនឹងលិខិតស្តាមអនុញ្ញាតិជាផ្លូវការ

ជាតិសាសន៍ដែលមិនទាន់ឮដំណឹងល្អមួយចំនួនធំ រស់នៅក្រោមរដ្ឋាភិបាលដែលប្រឆាំងនឹងដំណឹងល្អ ។ រដ្ឋាភិបាលទាំងនោះ មិនអនុញ្ញាតិអោយអ្នកណាម្នាក់ ទៅផ្សាយដំណឹងល្អ ក្នុងប្រទេសរបស់ពួកគេទេ ។ ក្រុមជំនុំ « លួចលាក់ » ត្រូវបានបង្កើតឡើង ដើម្បីផ្សាយដំណឹងល្អដោយសម្ងាត់ ។ អាចធ្វើដូចនេះបាន លុះត្រាតែក្លាហានណាស់ ។



១- ឧបសគ្គដែលកើតឡើង ដោយសារប្រទេសនៅឆ្ងាយៗពេក

ជាតិសាសន៍ដែលមិនទាន់ឮដំណឹងល្អ ភាគច្រើនស្ថិតនៅតំបន់ឆ្ងាយៗ ឬដាច់ស្រយាលតែឯង ។ បើសិនជាយើងគ្មានជំនឿខ្លាំងក្លាទេ យើងពិតជាមិនហ៊ានទៅទីកន្លែងនោះទេ ពីព្រោះឆ្ងាយផង ហើយថ្លៃចាយវាយក៏ច្រើនទៀត ។



នៅក្នុងកិច្ចការ ១:៨ ព្រះយេស៊ូបង្គាប់ពួកសាវ័កអោយចេញទៅស្រុកសាម៉ារី ដែលនៅជិតខាង និងដែលមានប្រពៃណីខុសគ្នា ។ តើទីកន្លែងណាមួយដែលតំណាង « ស្រុកសាម៉ារី » សំរាប់ក្រុមជំនុំរបស់អ្នក (ទីកន្លែងដែលមានវប្បធម៌ផ្សេង តែនៅក្បែរគ្នា) ?

សៀវភៅកិច្ចការ ជំពូក ១៣ ដល់ ២៨ បានរៀបរាប់អំពីដំណើរបេសកកម្មរបស់លោកប៉ូល ។ លោកប៉ូលបានធ្វើដំណើរទៅកាន់ស្រុកអាស៊ី ស្រុកក្រិក និងទីក្រុងរ៉ូម ដែលជារាជធានីរបស់ចក្រ-ភពរ៉ូម៉ាំង ដើម្បីផ្សព្វផ្សាយដំណឹងល្អ ។ ក្រុមជំនុំត្រូវបានបង្កើតនៅទីកន្លែងទាំងនោះ និងនៅតាមជាតិសាសន៍ ដែលនៅឆ្ងាយៗទៅទៀត ។

នៅក្នុងកិច្ចការ ១៥ ក្រុមប្រឹក្សាពិសេសមួយរបស់គ្រីស្តជនយូដានៅក្រុងយេរូសាឡឹម បានសំរេចចិត្តទទួលគ្រីស្តជនសាសន៍ដទៃ ។ គ្រីស្តជនទាំងនោះ មិនត្រូវកែប្រែវប្បធម៌របស់ខ្លួនដើម្បីអាចក្លាយជាបងប្អូនក្នុងព្រះគ្រីស្តឡើយ ។



នៅក្នុងសៀវភៅកិច្ចការ តើដំណឹងល្អរីកសាយដល់ទីណាខ្លះ ?

ពួកគេមិនបានរង់ចាំផ្សាយដំណឹងល្អដល់គ្រប់ទីក្រុងរបស់ស្រុកយូដាសិន ទើបចេញទៅសាម៉ារីទៀតទេ ។ ឯសាវ័កប៉ូល ក៏មិនស្ថិតនៅក្នុងតំបន់ណាមួយ រហូតទាល់តែបានផ្សាយដំណឹងល្អពេញតំបន់នោះដែរ ។ នៅពេលដែលគាត់ធ្វើកិច្ចការនៅកន្លែងថ្មីណាហើយ គាត់រៀបចំពួកចាស់ទុំកន្លែងនោះ អោយថែរក្សាក្រុមជំនុំដែលគាត់បានបង្កើត រួចគាត់ចេញទៅកន្លែងផ្សេងទៀត ដែលមិនទាន់បានឮដំណឹងល្អ ។ គាត់ធ្វើដំណើរឆ្ងាយពីស្រុកទេសរបស់គាត់ ដើម្បីផ្សាយដំណឹងល្អ និងបង្កើតក្រុមជំនុំថ្មី ។



ដោយសារយើងមានជំនឿរឹងមាំ និងអធិស្ឋានខ្លាំងក្លាណាស់ ទើបព្រះជាម្ចាស់កំទេចឧបសគ្គ ដើម្បីនាំឱ្យយើងអាចឆ្លងកាត់ឧបសគ្គទាំងនេះបាន :

ឧបសគ្គទាំងក្រាំដែលយើងត្រូវឆ្លងកាត់

ជាតិសាសន៍ទាំងឡាយដែលមិនទាន់ឮដំណឹងល្អ មានចំនួនពាក់កណ្តាលនៃចំនួនប្រជាជនទាំងអស់ នៅលើពិភពលោក ។ ផែនការរបស់ព្រះជាម្ចាស់ គឺឱ្យក្រុមគ្រួសារជាច្រើននៃគ្រប់ជាតិសាសន៍ និងគ្រប់ភាសា ចូលក្នុងវត្តមាន និង សិរីរុងរឿងរបស់ព្រះជា-ម្ចាស់ ។ ដើម្បីអាចសំរេចកិច្ចការដ៏អស្ចារ្យនេះបាន ព្រះជាម្ចាស់ចង់អោយអ្នកជឿបង្កើតក្រុមជំនុំ នៅក្នុងជាតិសាសន៍និមួយៗទាំងនោះ ។ មារសាតាំងខិតខំរារាំងយើង មិនអោយបំពេញតាមមហាបណ្តាំរបស់ព្រះជាម្ចាស់នោះទេ ។ មារសាតាំងបណ្តាយអោយយើងធ្លាក់ទឹកចិត្ត ដោយធ្វើអោយមានឧបសគ្គធំៗផ្សេងៗ :

«ដ្បិតយើងមិនមែនតយុទ្ធទល់នឹងមនុស្សទេ គឺតយុទ្ធទល់នឹងវត្ថុសក្តិសិទ្ធិ ទល់នឹងអ្វីៗដែលមានអំណាច ទល់នឹងមេត្រួតត្រាក្នុងលោកីយ៍ដ៏ងងឹតនេះ ហើយតយុទ្ធទល់នឹងឥទ្ធិពលអ្នកបិសាចដ៏អាក្រក់ទាំងឡាយ ដែលនៅស្ថានលើដែរ » ។

(អេភេសូ ៦:១២)

កិច្ចការរបស់ពួកអ្នកជឿ ដែលមានចែងនៅក្នុងសៀវភៅកិច្ចការ ជាគំរូសំរាប់យើងអំពីការផ្សាយដំណឹងល្អដល់ប្រជាជន ដែលមានវប្បធម៌ផ្សេង និងនៅប្រទេសឆ្ងាយៗ ។ ពួកគេចង់ផ្សាយដំណឹងល្អអោយដល់ចុងបំផុតនៃផែនដី ។ ទោះជាមានការខ្វះខាតខាងធនធាន ឬមានការបៀតបៀន ឬមានឧបសគ្គ ឬមានវប្បធម៌ខុសគ្នា ក៏ពួកគេនៅតែទៅដែរ ។

មហាបណ្តាំនៅក្នុងប្រវត្តិសាស្ត្រក្រុមជំនុំ

ចាប់តាំងពីសម័យកាលពួកសាវក រហូតមក ដំណឹងល្អបានរីកសាយពេញពិភពលោក ស្របតាមផែនការរបស់ព្រះជាម្ចាស់ ។ ដំណឹងល្អបានរីកសាយដល់គ្រប់ទ្វីបទាំងអស់ ដោយសារពលិកម្មរបស់គ្រីស្តជន ។

ក្រុមជំនុំដំបូងរីកចំរើនយ៉ាងឆាប់រហ័ស ហើយបានផ្សាយដំណឹងល្អដល់ទីក្រុងរ៉ូម ដែលសាវ៉កប៉ូលស្លាប់នៅទីនោះ ដោយសារព្រះនាមព្រះគ្រីស្ត ។ នៅទីក្រុងរ៉ូម ក្រុមជំនុំដំបូងរីកចំរើនរហូតដល់ចាក់បូសយ៉ាងជ្រៅ ហើយក្រោយមក បានក្លាយជា «ក្រុមជំនុំរ៉ូម៉ាំងកាតូលីក»។ ដំបូង ក្រុមជំនុំនេះផ្សាយដំណឹងល្អទូលំទូលាយ

ណាស់ ។ សាសនទូតត្រូវបានចាត់ឱ្យចេញទៅពេញទ្វីបអឺរ៉ុប ។ សាសនទូតទាំងនោះ ភាគច្រើនជាសង្ឃ ដែលថ្វាយខ្លួនដាច់ដល់ព្រះជាម្ចាស់ ។ ពួកគេលះបង់ក្រុមគ្រួសារ និងទ្រព្យសម្បត្តិ និងចំណងខាងលោកីយ៍ ដើម្បីធ្វើដំណើរទៅប្រទេសឆ្ងាយ និងទីកន្លែងប្រកបដោយគ្រោះថ្នាក់ ។ ពួកគេដូចសាវ័កប៉ូលដែរ គឺគ្មានប្រពន្ធទេ ហើយធ្វើការងារផ្សេង ដើម្បីផ្គត់ផ្គង់ខ្លួនឯង ។ ពួកគេប្តេជ្ញាចិត្តនៅលីវ រស់ក្នុងភាពក្រីក្រ និងស្តាប់តាមសេចក្តីបង្គាប់របស់ព្រះជាម្ចាស់ ។ សាសនទូតទាំងនេះច្រើននាក់ បានថ្វាយជីវិត ទំរាំអាចផ្សាយដំណឹងល្អដល់ពួកកុលសម្ព័ន្ធនៅអឺរ៉ុបបាន ។ ក្រុមជំនុំបានរីកសាយនៅប្រទេសអេស្ប៉ាញ ប្រទេសបារាំង ប្រទេសអាឡឺម៉ង់ និងចក្រភពអង់គ្លេស ។



ផ្នែកនៃដំណឹងល្អដែលត្រូវបញ្ជាក់ប្រាប់ ដើម្បីរំដោះពួកអ្នកដែលកាន់អបិយ៍ជំនឿ គឺ :

- ព្រះជាម្ចាស់បង្កើតអ្វីៗសព្វសារពើ គឺទាំងវត្ថុជាតិ ទាំងសត្វ ។ល។ (កំណើតពិភពលោក ១ និង ២) ។ ព្រះជាម្ចាស់មានអំណាចលើពិភពលោកទាំងមូល ។
- ព្រះជាម្ចាស់ជាព្រះអាទិករ មិនមែនជារបស់ដែលមនុស្សណាម្នាក់បង្កើតទេ ហើយព្រះអង្គបង្គាប់យើងកុំឱ្យថ្វាយបង្គំរបស់ដែលព្រះអង្គបានបង្កើត (សេរីភាព ២០:១-១៨, រ៉ូម ១:១៩-២៣) ។
- ព្រះយេស៊ូគ្រីស្តដែលជាព្រះបុត្រាព្រះជាម្ចាស់ មានអំណាចលើវិញ្ញាណគ្រប់យ៉ាង ។ ព្រះអង្គសង្គ្រោះយើង តាមរយៈការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ ។

ពួកអ្នកកាន់អបិយ៍ជំនឿ

នៅលើទ្វីបនិមួយៗ មានកុលសម្ព័ន្ធ ឬ ជនជាតិភាគតិចដែលកាន់អបិយ៍ជំនឿ «ជំនឿថាអ្វីៗទាំងអស់មានវិញ្ញាណ»។ ពួកអ្នកទាំងនោះជឿថា ដើមឈើ សត្វ ស្មឹង បឹង ផ្នាំងសិលា សុទ្ធតែមានវិញ្ញាណ ។ ពួកគេមិនទាន់ស្គាល់ព្រះយេស៊ូគ្រីស្តជាព្រះ-សង្គ្រោះ ដែលជាព្រះបុត្រាតែមួយអង្គរបស់ព្រះជាម្ចាស់នោះទេ ។ ពួកគេមិនទាន់ដឹងថា ព្រះអង្គមានអំណាចលើវិញ្ញាណគ្រប់យ៉ាងឡើយ ។ ពួកគេរស់នៅដោយភ័យខ្លាច និងដោយមានជំនឿឆ្វេងព្រោះពួកគេជឿថា វិញ្ញាណបានត្រួតត្រាលើអ្វីៗគ្រប់យ៉ាង នៅក្នុងជីវិតរបស់ពួកគេ ។ ពួកគេជឿថា វិញ្ញាណបណ្តាលអោយគេមានជំងឺ ទុរ្ភិក្ស ឬបញ្ហា ។ល។ ។ ដូច្នេះ ពួកគេធ្វើពិធីសាសនាផ្សេងៗដូចជាបញ្ចុះមន្តអាគមគាថា និងធ្វើអំពើអាបធ្មប់ ដើម្បីធ្វើអោយវិញ្ញាណទាំងនោះបានគាប់ចិត្ត ។



មួយរយៈក្រោយមក អ្នកដឹកនាំខ្លះរបស់ក្រុមជំនុំរ៉ូម៉ាំងកាតូលីកចាប់ផ្តើមបែកចេញពីសេចក្តីពិតរបស់ដំណឹងល្អ ។ មហិច្ឆិតារបស់ពួកសង្ឃទាំងនោះ គឺចង់បកស្រាយព្រះបន្ទូលព្រះជាម្ចាស់តែខ្លួនឯង អ្នកផ្សេងគ្មានសិទ្ធិបកស្រាយទេ ហើយពួកគេ«លក់»សេចក្តីសង្គ្រោះផងដែរ ។ ពួកអ្នកដឹកនាំទាំងនោះ បៀតបៀនពួកអ្នកដែលមិនទទួលស្គាល់អំណាចផ្តាច់ការរបស់ពួកគេ ។ លោកយ៉ូហានហ៊ុស ត្រូវគេដុតទាំងរស់ នៅឆ្នាំ ១៤១៥ ដោយសារគាត់បង្រៀនថា គ្រីស្តជនម្នាក់ៗមានសិទ្ធិអានព្រះគម្ពីរ និងធ្វើតាមសេចក្តីបង្រៀនក្នុងព្រះគម្ពីរ ពីព្រោះព្រះគម្ពីរជាអំណាចធំបំផុតសំរាប់អ្នកជឿ ។ នៅសម័យកាលនោះ គ្រីស្តជនជាច្រើនត្រូវគេសម្លាប់ចោល ដោយសារជំនឿរបស់ខ្លួន ។

ក្រុមជំនុំរ៉ូម៉ាំងកាតូលីក មិនអនុញ្ញាតិអោយបកប្រែព្រះគម្ពីរទេដើម្បីកុំអោយមនុស្សទូទៅ អាចសិក្សាព្រះគម្ពីរជាភាសារបស់ខ្លួនបាន ។ ហេតុនេះហើយបានជាដំណើរការផ្សាយដំណឹងល្អក៏លែងមានទៀត ។ ប៉ុន្តែនៅសតវត្សទី ១៦ ព្រះជាម្ចាស់បានកែប្រែក្រុមជំនុំរបស់ព្រះអង្គ ។

ដោយសារចលនាផ្សាយដំណឹងល្អរីកចំរើនឡើង ហើយការបកប្រែព្រះគម្ពីរចេះតែកើនឡើង ទើបគ្រីស្តជនជាច្រើនបែកចេញពីក្រុម

ជំនុំរ៉ូម៉ាំងកាតូលីក ដើម្បីអាចមានសិទ្ធិអាន និងធ្វើតាមព្រះ-គម្ពីរ ។ គ្រីស្តជនខ្លះទៀតទ្រាំនៅក្នុងក្រុមជំនុំរ៉ូម៉ាំង ដោយសង្ឃឹមថាគេអាចកែប្រែក្រុមជំនុំនេះពីខាងក្នុងបាន ។

ចាប់តាំងពីមាន « ចលនាកែប្រែរបស់ពួកប្រូតេស្តង់ » ដែលចាប់ផ្តើមនៅឆ្នាំ ១៥១៧ រហូតមក ព្រះគម្ពីរទាំងមូលបានត្រូវបកប្រែជាភាសារាប់រយ ។ គេត្រូវបកប្រែព្រះគម្ពីរជាភាសាផ្សេងៗថែមទៀត លើសពី២០០០ភាសា ។

ដំបូង ក្រុមជំនុំរ៉ូម៉ាំង :

- ☐ ថ្វាយបង្គំព្រះក្លែងក្លាយ និងត្រូវបានព្រះចៅអធិរាជរ៉ូម៉ាំងធ្វើការត្រួតត្រាខ្លាំងលើពួកគេ ។
- ☐ ផ្សាយដំណឹងល្អយ៉ាងទូលំទូលាយ និងស្មោះត្រង់ចំពោះព្រះបន្ទូលព្រះជាម្ចាស់ ។

ដំបូង ក្រុមជំនុំរ៉ូម៉ាំងធ្វើត្រឹមត្រូវតាមគោលការណ៍របស់ព្រះគម្ពីរ ហើយស្តាប់តាមព្រះបន្ទូល និងសេចក្តីបង្គាប់របស់ព្រះយេស៊ូ ។ ប៉ុន្តែ ក្រោយមក ក្រុមជំនុំក៏ធ្លាក់ចុះ ហើយបែរចេញពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។

ក្លែងបង្រៀនថា ព្រះយេស៊ូយាងឡើងទៅស្ថានសួគ៌ ដោយមិនបានសុគតទេ ។

សាសនាអ៊ីស្លាម ប្រហែលនឹងសាសនារបស់ពួកផារីស៊ី នៅក្នុងសម្ពន្ធមេត្រីថ្មី គឺពួកគេខិតខំសង្គ្រោះខ្លួនឯងដោយការប្រព្រឹត្តល្អ។ ពួកគេនៅមិនទាន់ដឹងថា ព្រះគ្រីស្តសង្គ្រោះមនុស្សតាមរយៈជំនឿ មិនមែនដោយសារការប្រព្រឹត្តអំពើល្អរបស់គេនោះទេ ។

តើពួកអ្នកជឿលើមហាម៉ាត់គិតថា ពួកគេបានសង្គ្រោះ ដោយរបៀបណា ?



អ្នកកាន់សាសនាអ៊ីស្លាម

អ្នកកាន់សាសនាអ៊ីស្លាម ភាគច្រើនរស់នៅក្នុងប្រទេសជាងសាម-សិប ពិសេស នៅប្រទេសអាហ្វ្រិកខាងជើង នៅមជ្ឈឹមបូពា (ប្រទេសអារ៉ាប់) និងនៅតំបន់អាស៊ីខាងត្បូង ។ ពួកអ៊ីស្លាមភាគច្រើន ជាអ្នកកាន់សាសនាអ៊ីស្លាមជ្រុលនិយម ។ ពួកគេចាត់សាសនទូតអ៊ីស្លាមអោយទៅប្រទេសផ្សេងៗ ដើម្បីនាំមនុស្សអោយជឿសាសនាអ៊ីស្លាម ។ ពួកអ៊ីស្លាមមិនអនុញ្ញាតិអោយសាសនទូតគ្រីស្តជនចូលទៅក្នុងប្រទេសរបស់ពួកគេទេ ។ ពួកអ្នកទាំងនេះបៀតបៀន និងសម្លាប់អ្នកដែលថ្វាយខ្លួនទៅព្រះគ្រីស្ត ។

ពួកអ៊ីស្លាមជឿលើព្រះមួយដែលគេហៅថា ព្រះអាឡា ។ ពួកគេទទួលភាគខ្លះរបស់គម្ពីរជាព្រះបន្ទូលរបស់ព្រះអាឡា ។ ប៉ុន្តែពួកគេជឿថា គ្រីស្តជនបានកែប្រែព្រះគម្ពីរ ។ ពួកគេមិនជឿថាព្រះគ្រីស្តជាព្រះបុត្រារបស់ព្រះជាម្ចាស់ និងជាព្រះសង្គ្រោះទេ ។ ពួកគេចាត់ទុកព្រះគ្រីស្តថា ជាព្យាការីម្នាក់តែប៉ុណ្ណោះ ។

ពួកអ៊ីស្លាមគោរពបូជាព្យាការីរបស់ពួកគេឈ្មោះម៉ូហាម៉ែត(មហា-ម៉ាត់) ដែលរស់នៅក្នុងសតវត្សទីដប់ប្រាំពីរ ។ ព្យាការីនេះ បានសរសេរគម្ពីរកូរ៉ង់ ដែលពួកអ៊ីស្លាមគោរពជាងព្រះគម្ពីរ ។ គម្ពីរ

តើការផ្សាយដំណឹងល្អទៅគ្រប់ជាតិសាសន៍ ប្រកបដោយប្រសិទ្ធិ-ភាព ត្រូវរាំងស្ទះដោយសារអ្វី ?

☐ គ្មានការបកប្រែព្រះបន្ទូលព្រះជាម្ចាស់ ជាភាសាផ្សេងៗរបស់ជាតិសាសន៍ទាំងឡាយ ។

☐ គ្មានមធ្យោបាយដឹកជញ្ជូន ឬ ធ្វើដំណើរ ។



ក្នុងចំណោមពួកសាសនទូតផ្សាយដំណឹងល្អដំបូង ដែលចេញពីអឺរ៉ុប មានក្រុមជំនុំម៉ូរ៉ាវី ។ ក្រុមជំនុំម៉ូរ៉ាវីចាប់ផ្តើមកកើត ដោយសារការភ្ញាក់រលឹកខាងព្រលឹងវិញ្ញាណមួយ ។ ព្រះជាម្ចាស់ធ្វើអោយមានក្រុមជំនុំនេះឡើង ដោយសារអ្នកដឹកនាំរបស់ក្រុមជំនុំនេះ ឈ្មោះអ្នកអង្គម្ចាស់ស៊ីនសេនឌ័រ (Count Zinzendorf) បានអធិស្ឋានយ៉ាងខ្លាំងក្លា ។ ក្នុងក្រុមជំនុំម៉ូរ៉ាវី ក្នុងសមាជិកហុកសិបនាក់ ត្រូវមានម្នាក់ចេញទៅក្រៅប្រទេស ធ្វើជាសាសនទូត ។ ដោយសារក្រុមជំនុំនេះក្រ ទើបពួកសាសនទូតទាំងនេះ មិនបានទទួលការផ្គត់ផ្គង់ជាប្រាក់កាសពីក្រុមជំនុំដើមរបស់ខ្លួននៅអឺរ៉ុបទេ។ គឺពួកគេធ្វើការងារដើម្បីផ្គត់ផ្គង់ខ្លួនឯង ដូចលោកប៉ូល ។



ពីវាលវដ្តសង្សា គឺការវិលកើតវិលស្លាប់ ហើយពួកគេស្វែងរកការបញ្ចប់ជីវិតតែម្តង ដោយខំកសាងបុណ្យកុសល ព្រោះពួកគេជឿថាជីវិតគឺជាទុក្ខ ។ ពុទ្ធសាសនិកជនខ្លះទៀតគោរពបូជាពុទ្ធរូបជាព្រះរបស់ខ្លួន ។ ពួកគេឧទ្ទិសទៅព្រះពុទ្ធ និងទៅព្រះឯទៀត ឬទៅវិញ្ញាណទាំងឡាយ សុំអោយជួយពួកគេនៅលើលោកនេះ ។

ពួកគេនៅមិនទាន់ស្គាល់ព្រះជាម្ចាស់ពិតប្រាកដតែមួយ និងដែលមានព្រះជន្មរស់ ដែលអាចជួយយើងអោយរួចពីសេចក្តីអាក្រក់ក្នុងជីវិតយើង តាមរយៈព្រះយេស៊ូគ្រីស្តនៅឡើយទេ ។

ពុទ្ធសាសនិកជនក៏ជឿដូចពួកហិណ្ឌូដែរថា មានការចាប់ជាតិជាថ្មី ។ តើការចាប់ជាតិជាថ្មីនេះ មានន័យយ៉ាងដូចម្តេច ?

តើយើងត្រូវប្រាប់ពួកគេអំពីអ្វី ដើម្បីអោយពួកគេអាចរួចផុតលែងគោរពព្រះក្លែងក្លាយ លែងមានជំនឿឆ្វេង និងលែងមានជំនឿខុសឆ្គងអំពីការវិលកើតវិលស្លាប់នៃការចាប់ជាតិជាថ្មី ?

ពុទ្ធសាសនិកជន

ពុទ្ធសាសនិកជនភាគច្រើនដែលមិនទាន់បានឮដំណឹងល្អ រស់នៅក្នុងប្រទេសអាស៊ីប៉ែកខាងត្បូង ប្រទេសម៉ុងហ្គោលី និងប្រទេសចិន ។

ពួកពុទ្ធសាសនិកជន កាន់តាមសេចក្តីបង្រៀនរបស់ព្រះសក្យមុនី-គោតម ដែលគេហៅថាព្រះពុទ្ធ ។ ព្រះពុទ្ធមានន័យថា «អ្នកត្រាស់ដឹងធម៌ ដែលជាអាថិកំបាំង » ។ ពួកគេជឿលើការចាប់ជាតិជាថ្មីរបស់មនុស្សដូចពួកហិណ្ឌូដែរ ។ ពុទ្ធសាសនិកជនខ្លះធ្វើសមាធិធម៌ក្នុងរយៈពេលយ៉ាងយូរ ។ ពួកគេស្វែងរកផ្លូវគេចចេញ

សាសនទូតដំបូងជាច្រើននាក់ ត្រូវស្លាប់ដោយសារមិនអាចទម្លាប់នឹងធាតុអាកាសបាន ឬដោយសារជួបប្រទះនឹងជម្ងឺប្លែកៗ ដែលពួកគេមិនធ្លាប់ជួបពីមុន ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ពួកគេនៅតែចេញទៅ ព្រោះពួកគេមានបំណងយ៉ាងខ្លាំងក្លាចង់ទៅផ្សាយដំណឹងល្អដល់តំបន់ឆ្ងាយៗបំផុតនៃផែនដី ដើម្បីធ្វើតាមបង្គាប់ព្រះជាម្ចាស់ ។ សាសនទូតជាច្រើនធ្វើដំណើរជាក្រុម ខ្លះទៀតធ្វើដំណើរម្នាក់ឯងជាអ្នកជំនួញ ។

តើសាសនទូតដំបូងភាគច្រើន ដែលផ្សាយដំណឹងល្អ ផ្គត់ផ្គង់ខ្លួនឯង ដោយរបៀបណា ?

នៅក្នុងឆ្នាំ **១៧៩២** លោកវីលីយ៉ាំការេ (William Carey) បានបង្កើតសមាគមសាសនទូត ហើយបានធ្វើដំណើរទៅប្រទេសឥណ្ឌា ។ នៅទីនោះលោក និងសហការីរបស់លោកបានបកប្រែព្រះគម្ពីរជាសាមសិបគ្រាមភាសា ។ បាវចនា (ពាក្យស្លោក គោលដៅ) របស់លោកគឺ : «អ្នកណាដែលសង្ឃឹមលើការអស្ចារ្យធំៗរបស់ព្រះជាម្ចាស់ អ្នកនោះនឹងខិតខំធ្វើអោយបានសំរេចកិច្ចការធំៗថ្វាយព្រះជាម្ចាស់ » ។





ពួកអ្នកកាន់សាសនាហិណ្ឌូថ្វាយបង្គំព្រះជាច្រើន ហើយព្រះខ្លះជាសត្វ ។ គេជឿដែរថា ក្រោយដែលស្លាប់ទៅ មនុស្សនឹងចាប់ជាតិឡើងវិញជាមនុស្ស ឬជាសត្វយោងទៅតាមអំពើ ដែលខ្លួនបានធ្វើពីជាតិមុន (ការចាប់ជាតិជាថ្មី) ។ ពួកគេគិតថា មនុស្សនឹងបន្តកើតស្លាប់ៗរហូតដល់លុបលាងអំពើបាបរបស់ខ្លួនអស់ ហើយបានឈានដល់ភាពបរិសុទ្ធឥតខ្ចោះ ។ ពួកគេជឿថា ទុក្ខលំបាកនៅក្នុងជីវិតជាលទ្ធផលនៃអំពើបាប ដែលមនុស្សបានធ្វើពីជាតិមុន ។ ពួកគេនៅមិនទាន់ដឹងថា ព្រះយេស៊ូគ្រីស្តអាចលើកលែងទោសអំពើបាបបាននោះឡើយ ។

នៅក្នុងប្រទេសចិនមាន «ជាតិសាសន៍» រាប់រយដែលមានភាសា និង វប្បធម៌ផ្សេងៗគ្នា ។ ជាតិសាសន៍ទាំងនោះ មានបណ្តាជនរាប់លាននាក់ តែមានអ្នកផ្សាយដំណឹងល្អតិចណាស់ ។

ជនជាតិចិនខ្លះកាន់សាសនាតាវ ខ្លះទៀតកាន់ពុទ្ធសាសនា ឬ សាសនាកុងហ្វ៊ូ ។

សូមអរព្រះគុណព្រះជាម្ចាស់ ដែលក្រុមជំនុំនៅប្រទេសចិនរីកចំរើនកាន់តែខ្លាំងឡើង ។ ប៉ុន្តែ នៅមានជនជាតិចិនរាប់រយលាននាក់ទៀត ដែលមិនទាន់បានឮដំណឹងល្អ ។

អ្នកកាន់សាសនាហិណ្ឌូ

អ្នកកាន់សាសនាហិណ្ឌូភាគច្រើន រស់នៅក្នុងប្រទេសឥណ្ឌា ។ ពួកគេជាមនុស្សដែលគោរពព្រះក្លែងក្លាយខ្លាំងជាងគេ ក្នុងពិភពលោកនេះ ។ ដំណឹងល្អបានចូលទៅដល់តំបន់ខ្លះនៃប្រទេសឥណ្ឌា ជាពិសេស តំបន់ខាងត្បូង ។ ប៉ុន្តែ នៅមានជនជាតិភាគតិចរាប់រយក្រុមទៀត ដែលមានភាសាផ្សេងៗ ដែលមិនទាន់បានឮដំណឹងល្អ ។

នៅក្នុងឆ្នាំ ១៨៤១ លោកដាវីឌ លីវីងស្តូន (David Livingston) បានចាប់ផ្តើមចូលទៅក្នុងព្រៃស្បាតរបស់ទ្វីបអាហ្វ្រិក ។ កិច្ចការនេះបានធ្វើអោយមានការភ្ញាក់ផ្អើល និងមានការចាប់អារម្មណ៍ជាខ្លាំង ដែលបណ្តាលអោយសាសនទូតរាប់រយនាក់ផ្សេងទៀត នាំគ្នាចូលទៅក្នុងទ្វីបអាហ្វ្រិក តាមគំរូរបស់គាត់ ។ ដោយសារតែការខំប្រឹងប្រែងរបស់ពួកអ្នកទាំងនេះ ទើបប្រជាជនអាហ្វ្រិកច្រើនលាននាក់បានថ្វាយខ្លួនទទួលជឿព្រះគ្រីស្ត ។



នៅក្នុងឆ្នាំ ១៨៨២ លោកហ្វ្រង់ស៊ីសប៉េនសុតទី (Francis Penzotti) ចាប់ផ្តើមនាំព្រះគម្ពីរទៅគ្រប់ប្រទេសរបស់ទ្វីបអាមេរិកឡាទីន ។ ទោះជាគាត់ត្រូវគេចាប់ឃុំឃាំង ដោយសារជំនឿរបស់គាត់ក៏ដោយ ក៏គាត់នៅតែបន្តធ្វើកិច្ចការគាត់តទៅទៀតដែរ ។ ដោយសារតែទឹកចិត្តនិមិត្តឃើញរបស់សាសនទូតទាំងឡាយ ដូចជាគាត់នេះ ទើបដំណឹងល្អ អាចរីកសាយ ស្ទើរតែពេញទ្វីបអាមេរិក-ឡាទីន ។



ជនជាតិចិន

ប្រទេសចិនជាប្រទេស ដែលមានប្រជាជនច្រើនជាងគេ នៅលើពិភពលោក ។ នៅក្នុងចំណោមប្រជាជនលើពិភពលោកប្រាំនាក់ មានជនជាតិចិនម្នាក់ ។ ដោយសារសព្វថ្ងៃនេះ ជនជាតិចិនរស់នៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលសង្គមនិយម ទើបជនជាតិចិនខ្លះក្លាយជាមនុស្ស ដែលគិតតែពីសម្ភារៈ ។ រដ្ឋាភិបាលនេះបានបៀតបៀនគ្រីស្តជនខ្លាំងណាស់ ។

ក្នុងចំណោមប្រជាជនលើពិភពលោកប្រាំនាក់ មានម្នាក់ជាជនជាតិចិន



នៅមានជាតិសាសន៍ជាច្រើន ដែលមិនទាន់មានក្រុមជំនុំ ។ នៅក្នុងប្រទេសខ្លះ សាសនទូតម្នាក់ខិតខំផ្សាយដំណឹងល្អប្រាប់មនុស្សរាប់លាននាក់ ។

តើប្រជាជនលើពិភពលោកចំនួនប៉ុន្មាន ដែលមិនទាន់បានឮដំណឹងល្អ ?

☐ មួយភាគបួន ។

☐ ពាក់កណ្តាល ។

ប្រជាជនលើពិភពលោកចំនួនពាក់កណ្តាលមិនទាន់បានឮដំណឹងល្អ ។

ប្រជាជនដែលមិនទាន់បានឮដំណឹងល្អ ស្ថិតនៅក្នុងក្រុមធំៗទាំងប្រាំខាងក្រោមនេះ :

- ជនជាតិចិន
- ពុទ្ធសាសនិកជន
- អ្នកកាន់សាសនាអ៊ីស្លាម
- អ្នកកាន់សាសនាហិណ្ឌូ
- ពួកអ្នកកាន់អបិយ៍ជំនឿ

ចាប់ពីឆ្នាំ១៨៦៥ទៅ ដោយសារតែលោកហ៊ុតសុនតៃល័រ (Hudson Taylor) មានការនិមិត្តឃើញអំពីការទៅផ្សាយដំណឹងល្អដល់ប្រទេសចិន ទើបលោកណែនាំប្រមូលគ្រីស្តទូតចំនួន៨០០នាក់ទៅធ្វើកិច្ច-ការនេះ ។ គាត់ជួបការលំបាកជាច្រើន គឺប្រពន្ធ និង កូនស្រីរបស់គាត់បានស្លាប់នៅប្រទេសចិន ហើយគាត់បានកប់សពអ្នកទាំងពីរនៅទីនោះ ។ ប៉ុន្តែ គាត់នៅតែព្យាយាមបំរើព្រះជាម្ចាស់នៅប្រទេសនោះបន្តទៀត ។ គាត់ និង គ្រីស្តទូតស្មោះត្រង់ជាច្រើនទៀត បានបន្សល់ទុកស្នាដៃដ៏ធំ នៅប្រទេសចិនដែលបន្តរីកចំរើនឡើងនៅពេលសព្វថៃ្ងនេះ ទោះជាមានការបៀតបៀនសាហាវយ៉ាងណាក៏ដោយ ។



ស្ត្រីជាច្រើនបានធ្វើជាសាសនទូត ។ នៅក្នុងសតវត្សទីម្ភៃនេះ អ្នកស្រីហេឡែនរ៉ូសីវែរ (Helen Roseveare) បានទៅផ្សាយដំណឹងល្អនៅប្រទេសកុងហ្គោ ដែលសព្វថ្ងៃគេហៅថា÷ «សាអៀរ» នៅអាហ្វ្រិកកណ្តាល ក្នុងឋានៈជាគ្រូពេទ្យសាសនទូត ។ ពីមុនអ្នកស្រីមានបំណងរៀបការ ប៉ុន្តែ ព្រះជាម្ចាស់មានផែនការផ្សេងសំរាប់អ្នកស្រី ហេតុនេះហើយបានជាអ្នកស្រីបំរើព្រះអង្គ ដោយនៅលីវ ។



តើក្រុមជំនុំអ្នកអាចធ្វើដូចម្តេច ដើម្បីជួយពង្រឹងចលនាសាសនទូតនេះ និងចូលរួមក្នុងចលនានេះ ?

តើកិច្ចការអ្វីទៀត ដែលត្រូវធ្វើ ?

តើយើងត្រូវធ្វើកិច្ចការអ្វីទៀត ដើម្បីបំពេញតាមមហាបណ្តាំ ដែលជាការអោយចេញទៅគ្រប់ជាតិសាសន៍នោះ ? តើនៅលើពិភពលោកនេះ កន្លែងណាដែលមិនទាន់មានសាវ័ករបស់ព្រះយេស៊ូ ?

ប្រជាជននៅលើពិភពលោក បានកើនចំនួនច្រើនណាស់ នៅក្នុងសតវត្សកន្លងទៅ ហេតុនេះហើយបានជាមានតែប្រជាជនចំនួនពាក់កណ្តាលប៉ុណ្ណោះ ដែលបានឮពីដំណឹងល្អ ។ នៅមានជនជាតិភាគតិចចំនួន ១២000 ក្រុមទៀត ដែលមិនទាន់មានក្រុមជំនុំ និងមិនទាន់មានអ្នកណាទៅផ្សាយដំណឹងល្អប្រាប់ ។

នៅពេលមានសង្គ្រាមទាមទារឯករាជ្យនៅប្រទេសកុងហ្គោ អ្នកស្រី
ត្រូវពួកទ័ពព្រៃចាប់ឃុំឃាំង និងធ្វើទារុណកម្មជាទម្ងន់ ។ ប៉ុន្តែ
អ្នកស្រីនៅតែព្យាយាមបំរើព្រះអង្គបន្តទៀត ។ អ្នកស្រីបានបង្កើត
មជ្ឈមណ្ឌលមួយ សំរាប់ការសិក្សាខាងវេជ្ជសាស្ត្រនៅប្រទេស-
កុងហ្គោ និងធ្វើជាទីបន្ទាល់ប្រកបដោយប្រសិទ្ធិភាពសំរាប់ប្រជា
ជននៅទីនោះ ។

នៅសម័យកាលថ្មីនេះ ក៏មានចលនាសាសនទូតធំៗដែរ ។ ព្រះ-
ជាម្ចាស់ត្រាស់ហៅបុរស និងស្ត្រី ដែលបានទទួលការនិមិត្តឃើញ
(មានទឹកចិត្តពុះពោរចង់ចេញទៅក្រៅផ្សាយដំណឹងល្អ) អោយធ្វើ
ជាសាសនទូត ។ បុរសស្ត្រីទាំងនេះ ក៏ណែនាំប្រមូលមនុស្សរាប់
ពាន់នាក់ទៀតអោយចេញទៅដែរ ។

យើងសរសើរដំកើងព្រះជាម្ចាស់ខ្លាំងណាស់ ព្រោះប្រទេសទាំង-
ឡាយ ដែលពីមុនមានពួកសាសនទូតមកផ្សាយដំណឹងល្អ ឥឡូវ
នេះ បានចាត់សាសនទូតខ្លួនឯងអោយចេញទៅដែរ ។

ចលនាសាសនទូតដ៏ធំនៅពេលសព្វថ្ងៃនេះ ដែលមានសាសនទូត
រាប់ពាន់នាក់ចេញពីក្រុមជំនុំថ្មីៗ នៅគ្រប់កន្លែងក្នុងពិភពលោក
បានចាប់ផ្តើម ដោយការអធិស្ឋានយ៉ាងខ្លាំង ។ ចលនានេះកើត

អ្នកផ្សាយដំណឹងល្អដែលជាជនជាតិអាហ្វ្រិក អាស៊ី និងអាមេរិក
ឡាទីនចំនួនជាង ១៥០០០នាក់ កំពុងបំរើព្រះជាម្ចាស់នៅប្រទេស
ក្រៅ ជាសាសនទូត ដែលក្រុមជំនុំរបស់ពួកគេចាត់ឱ្យចេញទៅ
អ្នកទាំងនោះភាគច្រើនក្រណាស់ ។ យើងត្រូវអធិស្ឋានទូលសូម
អោយព្រះជាម្ចាស់ ធ្វើឱ្យមានមនុស្សដូចនេះកាន់តែច្រើន ដើម្បីឱ្យ
គេអាចធ្វើអោយសំរេចតាមមហាបណ្តាំព្រះអម្ចាស់នៃចម្រូតនេះ
បាន (ម៉ាថាយ ៩:៣៧-៣៨) ។

តើព្រះជាម្ចាស់មានព្រះហឫទ័យឱ្យតែគ្រីស្តជន ដែលមកពីប្រទេស
មាន ធ្វើឱ្យសំរេចតាមមហាបណ្តាំរបស់ព្រះអង្គឬ ? តើផែនការ
អស់កល្បរបស់ព្រះជាម្ចាស់ពឹងផ្អែកលើអ្នកមានឬ ? លោកប៉ូល
បានមានប្រសាសន៍ថា ព្រះជាម្ចាស់ប្រើអ្វី ដែលមនុស្សលោកចាត់
ទុកថាទន់ខ្សោយ និងថោកទាប ដើម្បីផ្តាច់ពួកអ្នកមាន អ្នកខ្លាំង
ពូកែ និងអ្នកប្រាជ្ញ (១ កូរិនថូស ១:២៦-២៨) ។ សាសនទូត
អាចផ្តត់ផ្តង់ការរស់នៅរបស់ខ្លួន ដោយធ្វើការងារផ្សេងៗ ដូច
លោកប៉ូល និងពួកក្រុមជំនុំម៉ូរ៉ាវី និងសង្ឃសម័យដើមបានធ្វើ
ដែរ ។

ឡើងដោយសារបំណង ដែលចង់ធ្វើតាមបង្គាប់របស់ព្រះអម្ចាស់យេស៊ូគ្រីស្ត ។

ដោយសារតែទឹកចិត្តនិមិត្តឃើញដ៏ក្លាហានរបស់សាសនទូតទាំងអស់នេះ ទើបសព្វថ្ងៃនេះយើងបានទទួលសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ត ។ បើសិនជាពួកគេគ្រាន់តែចង់នៅក្នុងប្រទេសរៀងៗខ្លួន ដោយសារប្រជាជននៅក្នុងប្រទេសរបស់គេត្រូវការដំណឹងល្អដែរនោះ យើងមិនអាចទទួលដំណឹងល្អរបស់ព្រះគ្រីស្តបានទេ ។ សូមអរព្រះគុណព្រះជាម្ចាស់ ដែលពួកគេធ្វើតាមសេចក្តីបង្គាប់របស់ព្រះយេស៊ូគ្រីស្ត ! ។

នៅពេលសព្វថ្ងៃនេះ ចលនាសាសនទូតថ្មីមួយបានកើតឡើង ។ ចលនាសាសនទូតថ្មីនេះ មិនមែនចាប់ផ្តើមមកពីអឺរ៉ុប ឬពីសហរដ្ឋអាមេរិកនោះទេ តែចាប់ផ្តើមនៅក្នុងប្រទេសដែលកំពុងរីកចំរើន។ នៅក្នុងប្រទេសឥណ្ឌា ក្រុមជំនុំក្នុងស្រុកកំពុងចាត់សាសនទូតឱ្យចេញទៅកុលសម្ព័ន្ធក្នុងប្រទេសរបស់គេផ្ទាល់ និងទៅក្រៅប្រទេសទៀតផង ។ ទីភ្នាក់ងារសាសនទូតទាំងនេះខ្លះ មិនព្រមទទួលជំនួយពីក្រុមជំនុំនៅក្រៅប្រទេសឥណ្ឌាទេ ។ ពួកគេសុខចិត្តពឹងលើព្រះជាម្ចាស់ទាំងស្រុងវិញ ។ អង្គការសាសនទូតរបស់ពួកគេជាអង្គការជាតិ និងផ្គត់ផ្គង់ដោយខ្លួនឯង ។ ហេតុនេះហើយបានជាព្រះជាម្ចាស់ប្រទានពរដល់ពួកគេ ការងាររបស់ពួកគេបានលូតលាស់ល្អខ្លាំងជាងការងាររបស់អង្គការទាំងឡាយ ដែលពឹងផ្អែកលើធនធាន និងការដឹកនាំពីក្រៅប្រទេស ។

ភ្នាក់ងារសាសនទូតជាច្រើន ដែលចូលរួមក្នុងចលនាថ្មីនេះពឹងផ្អែកតែលើ :

- ☐ មូលនិធិបរទេស ។
- ☐ ធនធានផ្ទាល់របស់ពួកគេ ។



© Project WorldReach © SEAN